ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៥.......សហវ.[illegible]

# សារាចរណែនាំ
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជំនាន់ថ្មី

ដើម្បីរួមចំណែកអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងធានាដល់ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាមជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State Asset Register Management Information System-SARMIS)ជំនាន់ថ្មី និងបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលជាក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត និងនីតិបុគ្គលសាធារណៈ កាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២៤។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលជាក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត និងនីតិបុគ្គលសាធារណៈ ត្រូវអនុវត្តប្រព័ន្ធ SARMIS ជំនាន់ថ្មី ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២៥ តទៅ និងត្រូវអនុវត្តដូចខាងក្រោម៖

១. ត្រូវផ្តល់ទិន្នន័យទ្រព្យសម្បត្តិរដ្ឋជាឯកសារទន់ នៃបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួនក្នុងប្រព័ន្ធ SARMIS ជំនាន់ចាស់ មកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្ទេរចូលក្នុងប្រព័ន្ធ SARMIS ជំនាន់ថ្មី។ ករណីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋណា មិនបានផ្តល់ទិន្នន័យជាឯកសារទន់ មកទេ អាជ្ញាធរកាន់កាប់នោះត្រូវបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួនចូលក្នុងប្រព័ន្ធ SARMIS ជំនាន់ថ្មី ដោយខ្លួនឯង។

២. ដោយឆ្នាំ ២០២៥ នេះ ជាឆ្នាំដែលចាប់ផ្តើមអនុវត្តប្រព័ន្ធ SARMIS ជំនាន់ថ្មី លើកដំបូង ដូច្នេះ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួនក្នុងឆ្នាំ ២០២៤ ដែលជាឆ្នាំគោល ចូលក្នុងប្រព័ន្ធ SARMIS ជំនាន់ថ្មី ឱ្យរួចរាល់នៅត្រីមាសទី ១ នៃឆ្នាំ ២០២៥ និងត្រូវបិទបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២៤ ឱ្យបានចប់សព្វគ្រប់តាមនីតិវិធី និងចាប់ផ្តើមបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ២០២៥ ទៅតាមកាលបរិច្ឆេទជាក់ស្តែងជាធម្មតា។ ចំពោះឆ្នាំបន្តបន្ទាប់ ត្រូវបិទបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយកំណត់យក ថ្ងៃទី ៣១ ខែ ធ្នូ ជាកាលបរិច្ឆេទនៃការបិទបញ្ជី។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

៣.ត្រូវធ្វើបច្ចុប្បន្នភាពអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួន រួចធ្វើជាផ្លូវការមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងផ្ដល់ User Name និង Password ក្នុងការចូលប្រើប្រាស់ប្រព័ន្ធ SARMIS ជំនាន់ថ្មី។

៤.អង្គភាពប្រើប្រាស់ដែលទទួលបាន Username និង Password ក្នុងការចូលប្រើប្រាស់ប្រព័ន្ធ ត្រូវធានាថា មិនផ្ដល់ ឬ ចែកចាយ Username និង Password ដោយគ្មានការអនុញ្ញាតពីប្រធានគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួន បន្តទៅឱ្យមន្ត្រី ឬ បុគ្គលដែលពុំមានសមត្ថកិច្ចពាក់ព័ន្ធនោះឡើយ។

៥.ត្រូវបញ្ជូនសៀវភៅបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានបោះពុម្ពចេញពីប្រព័ន្ធ SARMIS ជំនាន់ថ្មី មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាធរមាន។

ទទួលបានសារាចរណែនាំនេះ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលជាក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត និងនីតិបុគ្គលសាធារណៈ ត្រូវសហការអនុវត្ត ឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២៥ តទៅ។

ថ្ងៃសុក្រ ១២រោច ខែមិគសិរ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ គ.ស. ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល ៖</u>**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាប"
- ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត និងនីតិបុគ្គលសាធារណៈ

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ